**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# លក្ខខណ្ឌយោង

**សម្រាប់បុគ្គលិកជាប់កិច្ចសន្យាចំនួន ៤រូប**

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកអាទិភាពគន្លឹះចំនួន ៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។ នៅក្នុងអាទិភាព បច្ចេកវិទ្យា គឺផ្តោតជាសំខាន់ក្នុងបច្ចុកោណទី ៥ ស្តីអំពី ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០២៥ រួចហើយផងដែរ ដែលអនុវត្តក្នុង ៣ ដំណាក់កាលគឺ ដំណាក់កាលទី ១ (២០២១-២០២៥)៖ ផ្តោតលើការកសាងមូលដ្ឋានគ្រឹះឌីជីថល និងការចាប់យកឌីជីថល, ដំណាក់កាលទី២ (២០២៦-២០២៣០)៖ ផ្តោតលើការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល និងដំណាក់កាលទី៣ (២០៣១-២០៣៥)៖ ផ្តោតលើការធ្វើបរិវត្តកម្មឌីជីថល។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរាជរដ្ឋាភិបាល លើការសម្របសម្រួល និងដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ផ្អែកតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ដោយមានអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលជាសេនាធិការបច្ចេកទេស។ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល បង្កើតឡើងក្នុងខែមិថុនា ឆ្នាំ២០២៣ ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម អនុលោមតាមគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល។

ដើម្បីគាំទ្រដល់បេសកកម្មខាងលើ, អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មានតម្រូវការជនជានមនុស្សជាបុគ្គលិកជាប់កិច្ចសន្យាចំនួន ៤រូប ដូចខាងក្រោម៖

- **អ្នកអភិវឌ្ឍកម្មវិធីវិប** (Full-Stack Developer) ១រូប
- **អ្នកអភិវឌ្ឍកម្មវិធីទូរសព្ទ** (Mobile Developer - Cross Platform) ១រូប
- **អ្នកគ្រប់គ្រងម៉ាស៊ីនមេ** (System Administrator) ១រូប
- **អ្នករចនារូបភាព** (Graphic Designer) ១រូប

## ភារកិច្ច និងគុណវុឌ្ឍិ

### អ្នកអភិវឌ្ឍកម្មវិធីវិប (Full-Stack Developer) - ១រូប

**ភារកិច្ច**

- ចូលរួមការងារប្រមូលនិងវិភាគលើតម្រូវការរបស់អ្នកប្រើប្រាស់និងផ្តល់ដំណោះស្រាយ
- ចូលរួមក្នុងការរៀបចំនិម្មាបនកម្ម, ការគូសប្លង់, ម៉ូដែល និងទម្រង់នៃសុសវែរ

- ចូលរួមសរសេរកូដកម្មវិធីផ្នែកខាងមុខ (Front-End Development)
- ចូលរួមសរសេរកូដអភិវឌ្ឍកម្មវិធីផ្នែកខាងក្រោយ (Back-End Development)
- ចូលរួមក្នុងការងារវិភាគ និងកសាងមូលទិន្នន័យ (Database)
- ចូលរួមពិភាក្សា និងកំណត់វិធីសាស្ត្រសម្រាប់ការរៀបចំ និងអភិវឌ្ឍសុសវែរ
- រៀបចំឯកសារបច្ចេកទេសពាក់ព័ន្ធនានានៅក្នុងវដ្តនៃការអភិវឌ្ឍសុសវែរ
- ចូលរួមធ្វើតេស្តផ្នែកបច្ចេកទេស និងមុខងាររបស់សុសវែរ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

**គុណវុឌ្ឍិ**

- មានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ, ព័ត៌មានវិទ្យា ឬប្រហាក់ប្រហែល
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ក្នុងការចូលរួមបង្កើតសុសវែរ
- មានបទពិសោធន៍ក្នុងការប្រើប្រាស់ Figma, Adobe XD ជាដើម
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍសុសវែរផ្នែកខាងមុខ ដោយប្រើប្រាស់ភាសាកូដ ដូចជា HTML, CSS និង JavaScript Framework ដូចជា React, Angular, Vue.js ឬផ្សេងទៀត
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍសុសវែរផ្នែកខាងក្រោយ ដោយប្រើប្រាស់ភាសាកូដ ដូចជា PHP, Java, Python, Node.js ជាដើម
- មានបទពិសោធន៍ក្នុងការប្រើប្រាស់ Web Development Framework ដូចជា Spring Boot, Laravel, Django, NextJS ជាដើម
- មានចំណេះដឹងលើការប្រើប្រាស់មូលទិន្នន័យ (Database Management) ដូចជា MySQL, MangoDB, PostgreSQL
- ចេះប្រើប្រាស់បច្ចេកវិទ្យា Container កាន់តែប្រសើរ ជាពិសេស Docker, Kubernetes
- មានបទពិសោធន៍ក្នុងការបង្កើតនិងប្រើប្រាស់ API
- មានជំនាញច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេស និងចាប់យកបានលឿនទៅលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ
- មានជំនាញក្នុងការសរសេរឯកសារ និងមានទំនាក់ទំនងការងារល្អ
- អាចបំពេញការងារដោយឯករាជ្យ និងជាក្រុមបានល្អ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, ឧស្សាហ៍, ព្យាយាម និងគោរពក្រមសីលធម៌វិជ្ជាជីវៈ។

## អ្នកអភិវឌ្ឍកម្មវិធីទូរសព្ទ (Mobile Developer) - ១រូប

**ភារកិច្ច**

- ចូលរួមអភិវឌ្ឍកម្មវិធីទូរសព្ទប្រភេទ Cross-Platform
- ចូលរួមនៅក្នុងវដ្តនៃគម្រោងទាំងមូល រួមមាន ការ Design, ការធ្វើ Prototype, ការសរសេរកូដ, ការធ្វើតេស្ត និងការដាក់ឱ្យប្រើប្រាស់កម្មវិធី
- សហការជាមួយអ្នកអភិវឌ្ឍកម្មវិធី និងអ្នកគ្រប់គ្រងផលិតផលដើម្បីបំផុសគំនិតថ្មី, បង្កើត, តេស្ត និងដាក់ដំណើរការផលិតផលផ្លូវការ

- ចូលរួមក្នុងដំណើរការវដ្តនៃកម្មវិធីទាំងមូលចាប់ពីការបំផុសគំនិត, ការរចនា, ការសង់, ការដំឡើង, ការតេស្ត និងការបញ្ចេញផលិតផលផ្លូវការទៅលើ Store និងគាំទ្រការប្រើប្រាស់
- បន្តកែលម្អកម្មវិធីឱ្យកាន់តែប្រសើរឡើង
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

**គុណវុឌ្ឍិ**

- សញ្ញាបត្របរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ, បច្ចេកវិទ្យាព័ត៌មាន ឬប្រហាក់ប្រហែល
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ក្នុងការចូលរួមបង្កើតកម្មវិធីទូរសព្ទ
- មានបទពិសោធន៍យ៉ាងតិច ១ ឆ្នាំជាមួយការប្រើប្រាស់ Flutter
- មានចំណេះដឹងផ្នែករចនា UX/UI កាន់តែប្រសើរ
- មានចំណេះដឹងលើ Native platform កាន់តែប្រសើរ
- យល់ដឹងពីឧត្តមានុវត្តន៍ និងផ្នែកសុវត្ថិភាពនៅលើថ្នាលទូរសព្ទ (Mobile Platform)
- ស្ទាត់ជំនាញជាមួយនឹងការប្រើប្រាស់ backend web service
- បទពិសោធន៍ជាមួយការប្រើប្រាស់ Git និងកម្មវិធីអភិវឌ្ឍផ្សេងទៀត
- បទពិសោធន៍ជាមួយមូលទិន្នន័យប្រភេទ In-memory
- អាចបំពេញការងារដោយឯករាជ្យ និងជាក្រុមបានល្អ
- មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាដោយខ្លួនឯង និងចូលចិត្តរៀនអ្វីថ្មីៗ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, ឧស្សាហ៍, ព្យាយាម និងគោរពក្រមសីលធម៌វិជ្ជាជីវៈ។

## អ្នកគ្រប់គ្រងកម្មវិធីម៉ាស៊ីនមេ (Application System Adminstrator) - ១រូប

**ភារកិច្ច**

- សម្របសម្រួល ប្រមូល និងវិភាគលើតម្រូវការរបស់អ្នកប្រើប្រាស់និងស្នើដំណោះស្រាយ
- គាំទ្រ និងត្រួតពិនិត្យជាប្រចាំរាល់មុខងារទាក់ទងនឹងម៉ាស៊ីនមេ និងមូលដ្ឋានទិន្នន័យ (Database) ដូចជាការតាមដាននិងត្រួតពិនិត្យ ការរក្សាទុកនិងទាញត្រលប់មកវិញ ការគ្រប់គ្រងឧប្បត្តិហេតុ
- រៀបចំ និងតំឡើងសូហ្វវែរផ្សេងៗស្របតាមនិម្មាបនកម្មរបស់ប្រព័ន្ធ ឬកម្មវិធី
- ចូលរួមក្នុងការរៀបចំនិម្មាបនកម្ម និងរចនាសម្ព័ន្ធមូលដ្ឋានទិន្នន័យ
- តាមដាន និងត្រួតពិនិត្យជាប្រចាំលើដំណើរការរបស់ម៉ាស៊ីនមេដើម្បីធានាបានលទ្ធផលតាមតម្រូវការ
- ចូលរួមកំណត់ និងរៀបចំស្តង់ដារនៃម៉ាស៊ីនមេដែលប្រើប្រាស់ជាក្របខណ្ឌរួម
- ផ្តួចផ្តើម ជំរុញ និងស្រាវជ្រាវពីនិន្នាការវិវត្តថ្មីៗពាក់ព័ន្ធនឹងដំណើរការនៃការគ្រប់គ្រងម៉ាស៊ីនមេ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

**គុណវុឌ្ឍិ**

- មានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ, ព័ត៌មានវិទ្យា ឬប្រហាក់ប្រហែល
- មានជំនាញច្បាស់លាស់ និងប្រើប្រាស់ជាប្រចាំលើប្រព័ន្ធប្រតិបត្តិការ Linux, Ubuntu
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ក្នុងការគ្រប់គ្រងកម្មវិធីម៉ាស៊ីនមេ ឬទាក់ទងនឹងផ្នែកសុវត្ថិភាពរបស់ម៉ាស៊ីនមេ និងមូលដ្ឋានទិន្នន័យមានបទពិសោធន៍លើការប្រើប្រាស់កម្មវិធីដូចជា Kubernetes, Docker, S3, Nginx, Apache

- មានចំណេះដឹងបន្ថែមលើការគ្រប់គ្រងមូលដ្ឋានទិន្នន័យ SQL និង NoSQL
- មានចំណេះដឹងបន្ថែមទាក់ទងនឹងផ្នែកសុវត្ថិភាពរបស់ម៉ាស៊ីនមេ និងមូលដ្ឋានទិន្នន័យ
- មានជំនាញច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេស និងចាប់យកបានលឿនទៅលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ
- មានជំនាញក្នុងការសរសេរឯកសារ និងមានទំនាក់ទំនងការងារល្អ
- អាចបំពេញការងារដោយឯករាជ្យ និងជាក្រុមបានល្អ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, ឧស្សាហ៍, ព្យាយាម និងគោរពក្រមសីលធម៌វិជ្ជាជីវៈ។

## អ្នករចនារូបភាព (Graphic Designer) - ១រូប

### ភារកិច្ច

- បង្កើតមាតិកាឌីជីថលសម្រាប់ផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយឌីជីថលដូចជា Facebook, Instagram, LinkedIn, គេហទំព័រ ជាដើម
- រៀបចំរចនារូបភាព និងព័ត៌មានក្រាហ្វ សម្រាប់ជំនួយដល់ការផ្សព្វផ្សាយ
- សហការជាមួយក្រុមការងារពាក់ព័ន្ធដើម្បីរៀបចំអត្ថបទផ្សព្វផ្សាយ
- ពិនិត្យ តាមដាន និងវិភាគលើស្ថិតិ និងលទ្ធផលការផ្សព្វផ្សាយតាមអត្ថបទនីមួយៗដើម្បីកំណត់វិធានក្នុងការពង្រឹង និងពង្រីកការផ្សព្វផ្សាយ
- រៀបចំយុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ស្របតាមគោលដៅរបស់អង្គភាព
- តាមដានជាប្រចាំពីនិន្នាការ និងការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយឌីជីថល
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ

### គុណវុឌ្ឍិ

- មានសញ្ញាបត្របរិញ្ញាបត្រឡើងក្នុងជំនាញប្រព័ន្ធផ្សព្វផ្សាយ ឬប្រហាក់ប្រហែល
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ លើការងាររៀបចំរូបភាព និងមាតិកាផ្សព្វផ្សាយ
- មានជំនាញក្នុងការស្រាវជ្រាវអត្ថបទសារព័ត៌មានបានល្អប្រសើរ
- មានបទពិសោធន៍ក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានលើគេហទំព័រកាន់តែប្រសើរ
- មានគំនិតច្នៃប្រឌិតពាក់ព័ន្ធនឹងការរចនារូបភាព, ក្រាហ្វិក
- មានចំណង់ចំណូលចិត្តនៅក្នុងវិស័យឌីជីថល
- មានជំនាញក្នុងការទំនាក់ទំនងបានល្អ
- អាចបំពេញការងារដោយឯករាជ្យ និងជាក្រុមបានល្អ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, ឧស្សាហ៍, ព្យាយាម និងគោរពក្រមសីលធម្មវិជ្ជាជីវៈ។

## ការកំណត់ពេលនៃកិច្ចសន្យា

កិច្ចសន្យាត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ១ឆ្នាំម្តង តាមគោលការណ៍កំណត់របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ថ្នាក់ដឹកនាំគ្រប់គ្រង

បេក្ខភាពដែលបានជ្រើសរើស នឹងត្រូវបំពេញតួនាទី និងភារកិច្ចនៅក្នុងអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមចាប់ពីថ្នាក់ការិយាល័យ, ថ្នាក់នាយកដ្ឋាន និងរហូតដល់ថ្នាក់អគ្គនាយក។

## ការរាយការណ៍

បុគ្គលិកជាប់កិច្ចសន្យា ត្រូវបំពេញការងារឱ្យបានល្អ និងម៉ត់ចត់ តាមតួនាទីដែលខ្លួនទទួលបន្ទុក, ដោយត្រូវរៀបចំរបាយការណ៍លទ្ធផលការងាររបស់ខ្លួនជាប្រចាំខែ និងដាក់ជូនថ្នាក់ដឹកនាំតាមឋានានុក្រមដែលបានកំណត់នៅក្នុងអង្គភាពដែលខ្លួនបំពេញការងារសម្រាប់ភ្ជាប់ការស្នើសុំការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែ។

## ទីតាំងបំពេញការងារ

បេក្ខភាពដែលបានជ្រើសរើសត្រូវបំពេញការងារនៅ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថិតនៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, មហាវិថីអូស៊ីអាយស៊ី, សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## បរិក្ខារ និងបរិស្ថានការងារ

បរិក្ខារការងារ ដូចជា តុការិយាល័យ កៅអី និងសេវាអ៊ីនធឺណិត នឹងត្រូវផ្តល់ជូនសម្រាប់បំពេញការងារ។ ដោយឡែក បេក្ខជន-បេក្ខនារីអាចប្រើប្រាស់កុំព្យូទ័រយួរដៃ ឬសម្ភារការិយាល័យផ្ទាល់ខ្លួនផ្សេងទៀតតាមការចាំបាច់របស់ខ្លួន សម្រាប់បំពេញការងារ និងសម្រេចលទ្ធផលការងារប៉ុន្តែត្រូវគោរពគោលការណ៍របស់អង្គភាព។ បេក្ខជន-បេក្ខនារីដែលបានជ្រើសរើសចូលបម្រើការងារមិនត្រូវបានអនុញ្ញាតឱ្យធ្វើការងារ និងទំនាក់ទំនងផ្សេងៗលើការងារផ្ទាល់ខ្លួនក្រៅពីការងារដែលចាត់តាំងដោយអគ្គនាយកដ្ឋានក្នុងកំឡុងម៉ោងការងារឡើយ។